ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation-Religion-King

រាជរដ្ឋាភិបាលកម្ពុជា
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
Council for the Development of Cambodia

*ថ្ងៃចន្ទ ២រោច ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩*
*រាជធានីភ្នំពេញ ថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៥*

# សេចក្តីប្រកាសព័ត៌មាន

## គម្រោងវិនិយោគចំនួន៦៧ ក្នុងទំហំទុនវិនិយោគសរុបប្រមាណ ៩៤៤លានដុល្លារអាម៉េរិក ត្រូវបានចុះបញ្ជីដោយគណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងខែកក្កដា ឆ្នាំ២០២៥

ក្នុងខែកក្កដា ឆ្នាំ២០២៥ គណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានសម្រេចចុះបញ្ជីគម្រោងវិនិយោគសរុបចំនួន**៦៧គម្រោង** ក្នុងទំហំទុនវិនិយោគសរុបប្រមាណ**៩៤៤លានដុល្លារអាម៉េរិក** និងអាចបង្កើតការងារបានប្រមាណ**៥៧ ៣ន់កន្លែង**។ ក្នុងចំណោមគម្រោងវិនិយោគសរុប គម្រោងវិនិយោគដែលមានទីតាំងស្ថិតនៅក្រៅតំបន់សេដ្ឋកិច្ចពិសេសមានចំនួន ៤៣គម្រោង និងគម្រោងវិនិយោគដែលមានទីតាំងស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសមានចំនួន ២៤គម្រោង។ ជារួម ការចុះបញ្ជីគម្រោងវិនិយោគមានការកើនឡើងចំនួន **២៣គម្រោង** ខណៈទំហំទុនវិនិយោគមានការកើនឡើងប្រមាណ **៥៤៧លានដុល្លារអាម៉េរិក** ស្មើនឹងប្រមាណ**១៣៨%** ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៤។ ទន្ទឹមនេះ បើគិតពីខែមករា ដល់ខែកក្កដា ឆ្នាំ២០២៥នេះ ការចុះបញ្ជីគម្រោងវិនិយោគមានចំនួន **៤៤០គម្រោង** គឺកើនឡើងចំនួន **២០៦គម្រោង** ស្មើនឹងប្រមាណ **៨៨%** ខណៈទំហំទុនវិនិយោគមានប្រមាណ **៦,៧៣ន់លានដុល្លារអាម៉េរិក** គឺកើនឡើងប្រមាណ **៣ពាន់លានដុល្លារអាម៉េរិក** ស្មើនឹងប្រមាណ **៨៤%** ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៤។ ជាការកត់សម្គាល់ ត្រឹមតែរយៈពេល៧ខែនៃឆ្នាំ២០២៥ គណៈកម្មាធិការវិនិយោគកម្ពុជា បានចុះបញ្ជីគម្រោងវិនិយោគលើសការចុះបញ្ជីគម្រោងវិនិយោគពេញមួយឆ្នាំ២០២៤ រហូតដល់ទៅ **២៦គម្រោង**។

គម្រោងវិនិយោគដែលមានភាពលេចធ្លោប្រចាំខែកក្កដា ឆ្នាំ២៩២៥ មានដូចខាងក្រោម៖

## ក. ក្រៅតំបន់សេដ្ឋកិច្ចពិសេស

| | |
|---|---|
| កសិកម្ម និងកសិ-ឧស្សាហកម្ម | **គម្រោងពង្រីកផលិតកម្មកសិដ្ឋានដាំដំណាំហូបផ្លែ និងរោងចក្រកែច្នៃ**<br>- **ទីតាំង៖** ស្រុកលំផាត់ ខេត្តរតនគិរី<br>- **ទំហំទុនវិនិយោគបន្ថែមប្រមាណ៖** ២២៦លានដុល្លារអាម៉េរិក<br>- **ការបង្កើតការងារ៖** ៨.៥៥០កន្លែង។ |
| ឧស្សាហកម្ម | **គម្រោងវិនិយោគអាជីវកម្មរ៉ែដែក**<br>- **ទីតាំង៖** ស្រុកឈូក, ស្រុកជុំគិរី, ស្រុកទឹកឈូ និងស្រុកដងទង់ ខេត្តកំពត<br>- **ទំហំទុនវិនិយោគ៖** ១៦៨លានដុល្លារអាម៉េរិក<br>- **ការបង្កើតការងារ៖** ៣៧៣កន្លែង។ |
| ទេសចរណ៍ | **គម្រោងវិនិយោគសាងសង់ និងអាជីវកម្មសណ្ឋាគារផ្កាយ៥ ចំនួន២២៧បន្ទប់**<br>- **ទីតាំង៖** ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>- **ទំហំទុនវិនិយោគប្រមាណ៖** ៨៥លានដុល្លារអាម៉េរិក<br>- **ការបង្កើតការងារ៖** ២៣០កន្លែង។<br>**គម្រោងវិនិយោគសាងសង់ និងអាជីវកម្មសណ្ឋាគារផ្កាយ៥ ចំនួន២៨០បន្ទប់**<br>- **ទីតាំង៖** ក្រុងបាវិត ខេត្តស្វាយរៀង<br>- **ទំហំទុនវិនិយោគប្រមាណ៖** ៦២លានដុល្លារអាម៉េរិក<br>- **ការបង្កើតការងារ៖** ៤៩៥កន្លែង។ |

## ខ. ក្នុងតំបន់សេដ្ឋកិច្ចពិសេស

| | |
|---|---|
| ឧស្សាហកម្ម | **គម្រោងវិនិយោគបង្កើតរោងចក្រផ្គុំដំឡើងគ្រឿងម៉ាស៊ីន និងរ៉ូបូត**<br>- **ទីតាំង៖** តំបន់សេដ្ឋកិច្ចពិសេស ចាងសានចាវ ស្ថិតនៅខេត្តស្វាយរៀង<br>- **ទំហំទុនវិនិយោគប្រមាណ៖** ១៣លានដុល្លារអាម៉េរិក<br>- **ការបង្កើតការងារ៖** ៤៣៣កន្លែង។ |

# គម្រោងវិនិយោគចាប់ពី
# ខែមករា ដល់ខែកក្កដា ឆ្នាំ២០២៥

ដែលត្រូវបានអនុម័តដោយគណៈកម្មាធិការវិនិយោគកម្ពុជា
នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**គម្រោងវិនិយោគ**
**៤៥០** (១៨១ គម្រោង ក្នុងតំបន់សេដ្ឋកិច្ចពិសេស)

**ទុនវិនិយោគ**
**៦,៧** ប៊ីលាន ដុល្លារអាម៉េរិក

**បង្កើតការងារ**
**~៣១២ពាន់** កន្លែង

## ទុនវិនិយោគតាមវិស័យ (គិតជាដុល្លារអាម៉េរិក)




## ប្រភពទុនវិនិយោគឈានមុខ

| | |
|---|---|
| 1. ចិន | ៤៣.៦៦% |
| 2. កម្ពុជា | ២៩.៩៧% |
| 3. សិង្ហបុរី | ៧.១០% |
| 4. វៀតណាម | ៥.៩៥% |
| 5. កោះ British Virgin | 0.៩០% |
| 6. អង់គ្លេស | 0.៤៩% |
| 7. កោះ Cayman | 0.៤៤% |
| 8. Bermuda | 0.៣៨% |
| 9. សហរដ្ឋអាម៉េរិក | 0.៣២% |
| 10. កោះ Samoa | 0.៣០% |

## របាយគម្រោងវិនិយោគនៅតាមបណ្តារាជធានី-ខេត្ត



ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
COUNCIL FOR THE DEVELOPMENT OF CAMBODIA

# គម្រោងវិនិយោគក្នុង ខែកក្កដា ឆ្នាំ២០២៥

ដែលត្រូវបានអនុម័តដោយគណៈកម្មាធិការវិនិយោគកម្ពុជា
នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**គម្រោងវិនិយោគ**
**៦៧** (២៤ គម្រោង ក្នុងតំបន់សេដ្ឋកិច្ចពិសេស)

**ទុនវិនិយោគ**
**៩៥៥** លានដុល្លារអាមេរិក

**បង្កើតការងារ**
**~៥៧ពាន់** កន្លែង

## ទុនវិនិយោគតាមវិស័យ (គិតជាដុល្លារអាមេរិក)




## ប្រភពទុនវិនិយោគឈានមុខ

| | |
|---|---|
| 1. ចិន | ៣៧.៨៩% |
| 2. កម្ពុជា | ៣១.២៤% |
| 3. វៀតណាម | ២៣.៩២% |
| 4. សិង្ហបុរី | ៣.៣៥% |
| 5. Bermuda | ២.៧២% |
| 6. កោះ Marshall | ០.៦២% |
| 7. បែលហ្ស៊ិក | ០.២៦% |

## របាយគម្រោងវិនិយោគនៅតាមបណ្ដារាជធានី-ខេត្ត

